00232737

C9/4/1

**នៅចំពោះមុខបុរេអង្គជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ-១៣)
ដាក់ទៅ: អង្គបុរេជំនុំជម្រះ
ថ្ងៃដាក់: ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨
ភាគីអ្នកដាក់: សហមេធាវីរបស់ **នួន ជា**
ភាសាដើម: អង់គ្លេស(ឯកសារដើម) និង ភាសាខ្មែរ(អត្ថបទបកប្រែ)
ប្រភេទឯកសារ: សាធារណៈ

---

**បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន**

---

**អ្នកដាក់ឯកសារ៖**
**សហមេធាវីរបស់ នួន ជា**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor KOPPE
លោក ម៉ម ចាន់ណា
លោក Andrew IANUZZI

**អ្នកទទួលឯកសារ៖**
**ចៅក្រមនៃអង្គបុរេជំនុំជម្រះ**
ប្រាក់ គឹមសាន
លោក ហួត វុទ្ធី
លោក Rowan DOWNING
លោក ន័យ ធុល
លោកស្រី Katinka LAHUIS
លោក ប៉ែន ពេជ្រសាលី

**សហព្រះរាជអាជ្ញា៖**
អ្នកស្រី ជា លាង
លោក Robert PETIT
លោក តាន់ សេណារ៉ុង
លោក Anees AHMED

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 16 / 10 / 2008
ម៉ោង (Time/Heure): 15:35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 17 / 10 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៧៣, ៧៤ និង ៧៥ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហមេធាវីរបស់ជនត្រូវចោទ នួន ជា (ហៅថា"មេធាវីការពារ") តទៅនេះសូមដាក់សារណាបណ្តឹងឧទ្ធរណ៍នេះទៅអង្គបុរេជំនុំជម្រះ (ហៅថា"អ.ប.ជ") "ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន" (ហៅថា"ដីកាបន្តថេរៈវេលា"[1]) ដែលចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា"ក.ស.ច.ស") ។ រាល់មូលហេតុដូចដែលបានបញ្ជាក់ជូនខាងក្រោមនេះ មេធាវីការពារសន្និដ្ឋានថា: (i) បណ្តឹងឧទ្ធរណ៍គឺអាចទទួលយកបាន, (ii) ការបន្តឃុំខ្លួនលោក នួន ជា គឺមិនត្រឹមត្រូវទាំងអង្គហេតុ និង អង្គច្បាប់, (iii) ដីកាបន្តថេរៈវេលា គឺខុសនឹងនីតិវិធី និង (iv) ការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយភ្ជាប់ជាមួយលក្ខខណ្ឌ គឺសមស្របក្រោមកាលៈទេសៈនេះ ។

## II. អង្គហេតុពាក់ព័ន្ធ

2. លោក នួន ជា កំពុងទទួលរងនូវការចោទប្រកាន់ដោយការិយាល័យសហព្រះរាជអាជ្ញា (ហៅថា "ក.ស.ព") ពីបទទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មខុសៗគ្នាជាងម្ភៃ តាមរយៈទម្រង់នៃការទទួលខុសត្រូវផ្សេងៗគ្នាចំនួនប្រាំពីរ (៧) ដែលត្រូវបានប្រព្រឹត្តនៅទីតាំងជាងម្ភៃប្រាំមួយ (២៦) កន្លែងនៅលើទឹកដីនៃកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩[2] ។ តាមអំណាចនៃការចោទប្រកាន់ទាំងនេះ លោក នួន ជា ត្រូវបានចាប់ខ្លួន និងបញ្ជូនមកចំពោះមុខ ក.ស.ច.ស ហើយត្រូវបានចោទប្រកាន់ជាផ្លូវការពីការធ្វើផែនការ ញុះញង់ បញ្ជា ប្រព្រឹត្ត និងជួយ

---

[1] សូមមើលឯកសារលេខ C-9/3 ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៨ ។

[2] សូមមើលឯកសារលេខ C-9/2, "ការជំទាស់តវ៉ាទៅនឹងការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ (ហៅថា"ការជំទាស់តវ៉ាទៅនឹងការបន្តថេរៈវេលានៃការឃុំខ្លួន") កថាខណ្ឌ ២ ដល់ ៤ (ដែលបានសំអាងលើឯកសារលេខ D-3 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យទៅស៊ើបសួរ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧, កថាខណ្ឌ ៣៧ ដល់ ៧២, កថាខណ្ឌ ៧៥ ដល់ ៨១, កថាខណ្ឌ ១១៥, ១១៧ និង ១២២ និងឯកសារលេខ D-83 "ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យទៅស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងមន្ទីរសន្តិសុខរបស់ភូមិភាគឧត្តរ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ (ហៅថា"ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យទៅស៊ើបសួរបន្ថែម" កថាខណ្ឌ ៥ ដល់ កថាខណ្ឌទី១១) ។

និងជម្រុញក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩[3] ។

3. ផ្អែកតាមការចោទប្រកាន់របស់ខ្លួន ព្រមជាមួយឯកសារបន្ថែមដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ក.ស.ព បានអះអាងថា លក្ខខណ្ឌភ្ជាប់របស់វិធាន ៦៣(៣) ត្រូវបានបំពេញ ហើយអាស្រ័យហេតុនេះ លោក **នួន ជា** ត្រូវតែឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនការ[4] ។ ជាពិសេស ក.ស.ព បានទាញហេតុផលថា (i) មានមូលហេតុដែលនាំឲ្យជឿជាក់យ៉ាងច្បាស់ថា លោក **នួន ជា** បានចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងថា (ii) ការឃុំខ្លួនបណ្ដោះអាសន្នមានលក្ខណៈចាំបាច់ ដើម្បីបង្ការរាល់ការដាក់សម្ពាធលើសាក្សី បង្ការការបំផ្លាញភស្តុតាង ធានារក្សាទុកវត្តមានរបស់ជននេះសម្រាប់ដំណើរការនីតិវិធី និងដើម្បីរក្សាសុវត្ថិភាពដល់ជនត្រូវចោទផ្ទាល់ និងដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈ[5] ។

4. លើសពីការជំទាស់តវ៉ារបស់លោក **នួន ជា** ក.ស.ច.ស បានយល់ស្របតាមសំណើរបស់ ក.ស.ព យ៉ាងប្រញ៉ាប់ប្រញាល់ ដោយធ្វើការគាំទ្រលើសេចក្ដីសន្និដ្ឋាននីមួយៗរបស់ ក.ស.ព ទាក់ទងនឹងលក្ខណៈវិនិច្ឆ័យខុសៗគ្នារបស់វិធាន៦៣(៣)[6]។ ក.ស.ច.ស មិនបានបញ្ជាក់ភស្តុតាងជាក់លាក់ទេ ហើយក៏មិនមានការគាំទ្ររឹងមាំដល់ដីកានេះដែរ ។ សំខាន់ជាងនេះទៅទៀត ពុំមានវិធានការផ្សេង (ឧទាហរណ៍ វិធានការធូរស្រាល) ត្រូវបានយកមកពិចារណានោះឡើយ ។

5. មេធាវីការពារបានសន្និដ្ឋាននៅក្នុងសារណាបណ្ដឹងឧទ្ធរណ៍ថា (i) ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីភ្ជាប់លោក **នួន ជា** ទៅនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នោះទេ និង (ii) លក្ខណៈវិនិច្ឆ័យ

---

[3] សូមមើលឯកសារលេខ C-6 “ដីកាបង្គាប់ឲ្យនាំខ្លួន” ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០០៧, ឯកសារលេខ. D-20 “កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៧ ទំព័រ ២ ដល់ ៣ ។

[4] សូមមើលឯកសារលេខ. C-8 “កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃសវនាការតទល់គ្នា” ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៧ ។

[5] ដូចខាងលើ ។

[6] សូមមើលឯកសារលេខ C-9 “ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន” ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ កថាខណ្ឌ ៥ ដល់ទី៦ (ហៅថា “ដីកាឃុំខ្លួនបណ្ដោះអាសន្ន”) ។

នីមួយៗនៃវិធាន ៦៣(៣)(ខ) ត្រូវបានគាំទ្រដោយសញ្ញាណអរូបី ជាជាងអង្គហេតុជាក់ស្តែង[7] ។ អាស្រ័យហេតុនេះ មេធាវីការពារបានស្នើសុំនូវលក្ខខណ្ឌជាច្រើនសម្រាប់ការដាក់លោក **នួន ជា** ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ដែលមានគោលបំណងកាត់បន្ថយការព្រួយបារម្ភដោយស្មានៗទាំងនេះ[8] ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គបុរេជំនុំជម្រះបានតម្កល់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទាំងស្រុង ដោយដាក់ជំនួសមកវិញនូវការវិភាគរបស់ខ្លួនសម្រាប់ "មូលហេតុទាំងអស់" របស់ ក.ស.ច.ស[9] ។ សំណើរបស់មេធាវីស្នើសុំដាក់លោក **នួន ជា** ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ត្រូវបានបដិសេធភ្លាមៗ ហើយក៏មិនមានការពិចារណានូវជម្រើសផ្សេងៗដែរ[10] ។

6. បន្ទាប់ពីបានទទួលនូវសេចក្តីជូនដំណឹងពីគោលបំណងរបស់ ក.ស.ច.ស ដើម្បីបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នលោក **នួន ជា** មួយឆ្នាំបន្ថែមទៀតនោះ មេធាវីការពារក៏បានជំទាស់ភ្លាមៗដែរ។ ខណៈយល់ស្របថាមានអត្ថិភាពនៃមូលហេតុដែលនាំឲ្យជឿជាក់យ៉ាងច្បាស់ថាលោក **នួន ជា** បានប្រព្រឹត្តិឧក្រិដ្ឋកម្មមួយចំនួនដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[11]ក៏ដោយ ក៏មានការទាញហេតុផលថា លក្ខណៈវិនិច្ឆ័យនៃវិធាន ៦៣(៣)(ខ) មិនត្រូវ (និងមិនដែលធ្លាប់បាន) បានបំពេញទៀតឡើយ[12] ។ បន្ថែមពីលើនេះ មេធាវីការពារបានសន្និដ្ឋានថាដីកាឃុំខ្លួនបណ្តោះអាសន្ន គឺខុសនឹងនីតិវិធី ដោយសារតែការខកខានមិនបានបង្ហាញពីមូលដ្ឋានអង្គហេតុសម្រាប់ការឃុំខ្លួន ហើយបានជម្រុញឲ្យ ក.ស.ច.ស បញ្ចៀសនូវកំហុសស្រដៀង

---

7 សូមមើលឯកសារលេខ C-11/4 បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន" ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០០៧ (ហៅថា"បណ្តឹងឧទ្ធរណ៍") កថាខណ្ឌ ៤១ ដល់ទី ៥៣ ។

8 ដូចខាងលើ កថាខណ្ឌ ៥៥ ដល់ ៥៨ និង ឧបសម្ព័ន្ធ ក ។

9 សូមមើលឯកសារលេខ C-11/54 "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៨ (ហៅថា "សាលដីកា") កថាខណ្ឌ ៤១ ដល់ទី ៨១ ទំព័រ ២៨ ។

10 ដូចខាងលើ កថាខណ្ឌ ៨៣ ។

11 សូមមើលការជំទាស់តវ៉ាទៅនឹងការបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ១០ ។

12 ដូចខាងលើ កថាខណ្ឌ ១១ ។

គ្នានេះនៅក្នុងដីកាថ្មីរបស់ខ្លួន[13] ។ ជាចុងក្រោយ មេធាវីការពារស្នើសុំជាថ្មីម្តងទៀតឱ្យដោះលែងលោក នួន ជា "ដោយភ្ជាប់ជាមួយនូវលក្ខខណ្ឌសមហេតុផលដែលអាចធានាវត្តមានរបស់គាត់នៅសវនាការណាមួយនាថ្ងៃអនាគត់"[14] ។

7. ចំពោះការជំទាស់តវ៉ាទាំងនេះ និងទោះបីជាមានសំណើសុំឱ្យមានការបញ្ជាក់ជាក់លាក់ក៏ដោយ ក៏ ក.ស.ច.ស បានបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នលោក នួន ជា មួយឆ្នាំបន្ថែមទៀតនៅក្នុងដីកាដែលមានអត្ថន័យមិនច្បាស់លាស់រហូតមកដល់បច្ចុប្បន្ននេះ ។ ជាថ្មីម្តងទៀតសំណើសុំដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការត្រូវបានបដិសេធ ហើយវិធានការផ្សេងទៀតក៏មិនបានពិចារណាដែរ ។

## III. ច្បាប់ពាក់ព័ន្ធ

### ក. យុត្តាធិការរបស់អង្គបុរេជំនុំជម្រះ

8. វិធាន ៧៣ ផ្តល់ឱ្យអង្គជំនុំជម្រះនូវ "សមត្ថកិច្ចផ្តាច់មុខ [...] លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដូចដែលមានចែងនៅក្នុងវិធាន ៧៤" ។ អនុលោមទៅតាម ៧៤(៣)(ច) ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត "ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ" ។ ចំនុចនេះត្រូវបានគេសន្មត់ថា រួមបញ្ចូលទាំងដីកាបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន "ដែលបើកផ្លូវប្តឹងឧទ្ធរណ៍"[15] ។

### ខ. បទដ្ឋាននៃការពិនិត្យបណ្តឹងឧទ្ធរណ៍ឡើងវិញ

9. អនុលោមទៅតាមការអនុវត្តលើបណ្តឹងឧទ្ធរណ៍របស់ប្រព័ន្ធច្បាប់ស៊ីវិល ដែលមានមូលដ្ឋានគ្រឹះសយ៉ាងរឹងមាំ អង្គជំនុំជម្រះនេះគប្បីពិនិត្យ*ជាថ្មី*លើបញ្ហាឃុំខ្លួនបណ្តោះអាសន្ន ដោយពុំចាំបាច់

---

[13] ដូចខាងលើ កថាខណ្ឌ ១២ ដល់ទី ១៤ ។

[14] ដូចខាងលើ កថាខណ្ឌ ១១ (យោងទៅលើសំណើដើមដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធ ក នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន) ។

[15] វិធាន ៦៧(៧) ។

ពិចារណាលើការរកឃើញផ្អែកអង្គច្បាប់ ឬ អង្គហេតុរបស់ ក.ស.ច.ស ឡើយ ។ នៅក្នុងការសម្រេចសេចក្តី អង្គបុរេជំនុំជម្រះមានឆន្ទានុសិទ្ធិគ្មានដែនកំណត់ក្នុងការតម្កល់ កែប្រែ ឬ ផ្អាកដីកាឃុំខ្លួនបណ្តោះអាសន្ន ផ្អែកលើសំណុំរឿងដែលមាន និងព័ត៌មានបន្ថែមដែលបង្ហាញដោយភាគីនៃបណ្តឹងឧទ្ធរណ៍[16] ។

## គ. លក្ខខណ្ឌ និង ការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

10. មេធាវីការពារស្នើសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាលើសារណានៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ននៅត្រង់កថាខណ្ឌ ២៤ ដល់ទី ២៩ និង កថាខណ្ឌ ៨ ដល់ទី៩ នៃការជំទាស់តវ៉ាទៅនឹងការបន្តថេរៈវេលានៃការឃុំខ្លួន។ វាជាការរំលឹកឡើងវិញថា យុត្តិសាស្ត្រសិទ្ធិមនុស្សដែលអាចអនុវត្តបាន បានរកឃើញជារឿយៗថា ហានិភ័យលើកដំបូងដែលធ្វើជាយុត្តិកម្មសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន (ឧទាហរណ៍ ហានិភ័យដែលមានចែងនៅក្នុងវិធាន ៦៣(៣)(ខ)) បានថយចុះជាបណ្តើរៗ។ តាមពិត ការពឹងអាស្រ័យទៅលើករណីយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប(ហៅថា“ECHR") អង្គជំនុំជម្រះនេះបានធ្វើការកត់សម្គាល់កាលពីពេលថ្មីៗនេះថា " ខណៈពេលដែលហានិភ័យជាទូទៅត្រូវបានបង្កើត [...] “ប្រហែលអាច” ទទួលយកមកធ្វើជាមូលដ្ឋានសម្រាប់ការឃុំខ្លួននៅដំណាក់កាលដំបូងនៃដំណើរការនីតិវិធី ព្រមជាមួយនឹងការកន្លងផុតនៃពេលវេលា គេចាំបាច់ត្រូវមានកត្តាមួយផ្សេងទៀតដែលអាចបង្ហាញថា *ហានិភ័យនេះពិតជាមានអត្ថិភាពមែន*"[17]។

---

[16] សូមមើលឯកសារ C-22/I/29 អង្គបុរេជំនុំជម្រះ “សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី ដែលស្នើសុំការអនុញ្ញាតឱ្យផ្អាកការពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនចំពោះការឃុំខ្លួនបណ្តោះអាសន្ន និងសំណើសុំឱ្យមានដីកាណែនាំដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីអនុញ្ញាតឱ្យលោក អៀង សារី បានសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ៧ (“អង្គបុរេជំនុំជម្រះមានយុត្តាធិការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់លោក អៀង សារី ដើម្បីកែប្រែលក្ខខណ្ឌនៃការឃុំខ្លួន និង ផ្អាកលក្ខខណ្ឌនៃការឃុំខ្លួន”) ។

[17] ឯកសារលេខ 33/I/7 អង្គបុរេជំនុំជម្រះ “សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន” ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០៨ កថាខណ្ឌ ១៥ (បញ្ជាក់នៅក្នុងអត្ថបទដើម) ។ នៅក្នុងករណីនេះ អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់អំពីហានិភ័យដែលចុងចោទអាចដាក់0សម្ពាធទៅលើសាក្សី ឬរំខានដល់កិច្ចដំណើរការនីតិវិធី

## ឃ. សិទ្ធិចំពោះដីកាមានមូលហេតុ

11. អនុលោមទៅតាមវិធានផ្ទៃក្នុង ដីកាឃុំខ្លួនបណ្តោះអាសន្នត្រូវតែ "បញ្ជាក់ពីអំពីអង្គហេតុ និង អង្គច្បាប់សម្រាប់ជាមូលដ្ឋាននៃការឃុំខ្លួន"[18] ។ រាល់ដីកាបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ជាក់ពីមូលហេតុដូចគ្នាផងដែរ[19] ហើយគ្រាន់តែមានសេចក្តីយោងចំពោះបញ្ញត្តិច្បាប់ប៉ុណ្ណោះ គឺមិនគ្រប់គ្រាន់នោះទេ[20] ។ សំខាន់ជាងនេះទៅទៀត ការវិភាគបែបអរូបី ឬ ការវិភាគរាក់កំផែល គឺមិនគ្រប់គ្រាន់នោះទេ តែតុលាការដែលមានសមត្ថកិច្ចលើករណីនេះ ត្រូវតែ "កត់ត្រារាល់អំណះអំណាងទាំងអស់ដែលគាំទ្រដល់ការដោះលែង និងអំណះអំណាងដែលប្រឆាំងនឹងការដោះលែង នៅក្នុងដីកាសម្រេចមានមូលហេតុ"[21]។ មូលហេតុមានពីរៈ ទី១ គឺដើម្បីអនុញ្ញាតឱ្យជនត្រូវចោទប្រើសិទ្ធិរបស់ខ្លួនដើម្បីប្តឹងឧទ្ធរណ៍ប្រកបដោយប្រសិទ្ធិភាព និងទី២ ដើម្បីរក្សាទំនុកចិត្តរបស់សាធារណៈជនទៅលើដំណើរការស្វែងរកយុត្តិធម៌[22] ។

## ង. ការដោះលែងឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន

12. មេធាវីការពារក្តីស្នើសុំឱ្យពិចារណាកថាខណ្ឌ ៣០ នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន។

13. បន្ថែមពីលើនេះទៀត គេបានកត់សម្គាល់ឃើញថា ការរែករញែកចំពោះការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន កើតមានឡើងរវាងស្ថាប័នសិទ្ធិមនុស្ស និង តុលាការអន្តរជាតិ ក្នុងខណៈ

---

ដោយសារមូលហេតុថា ចុងចោទជាសមាជិកមួយរូបនៅក្នុងក្រុម)។ ដូចខាងលើ កថាខណ្ឌ ២១ ("ដោយសារការកន្លងផុតនៃពេលវេលា និន្នាការមានការកើនឡើងនៅពេលដែលការស៊ើបអង្កេតកំពុងតែដំណើរការ និងហានិភ័យមានការថយចុះ" ។

[18] វិធាន ៦៣(២)(ក) ។

[19] សូមើលវិធាន ៦៣(៧) ("រាល់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវមានសំអាងហេតុចំពោះការបន្តឃុំខ្លួនបណ្តោះអាសន្ន") ។

[20] សូមមើលករណី Jessica Simor និង Ben Emmerson QC, HUMAN RIGHTS PRACTICE, (Sweet & Maxwell 2006), § 5.045 ។

[21] ដូចខាងលើ § 5.052 ។

[22] ដូចខាងលើ § 5.044 ( "គោលបំណងនៃកាតព្វកិច្ចផ្តល់មូលហេតុ គឺដើម្បីជំរុញឱ្យត្រូវជាប់ឃុំដាក់សំណើទៅតុលាការ ដើម្បីតវ៉ាអំពីភាពស្របច្បាប់នៃការឃុំខ្លួន [...]) ។

ដែលស្ថាប័នសិទ្ធិមនុស្ស "មិនពេញចិត្តចំពោះការឃុំខ្លួនបណ្ដោះអាសន្ន ហើយបានដាក់បន្ទុកទៅឱ្យរដ្ឋធ្វើយុត្តិកម្មចំពោះការបន្តឃុំខ្លួន" ចំណែកឯតុលាការអន្តរជាតិ "បានលើកឡើងថា ការដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន គឺជាអញ្ញត្រកម្ម ហើយនៅក្នុងការអនុវត្តជាក់ស្តែង បានដាក់បន្ទុកទៅលើមេធាវីការពារក្តីឱ្យបង្ហាញថា ការដោះលែងត្រូវតែបានធានា"[23]។ ការឃ្លាតឆ្ងាយពីគ្នាបែបនេះត្រូវបានពន្យល់ត្រួសៗដោយភាសារបស់ "វិធាននីតិវិធី និង ភស្តុតាង"ផ្សេងៗរបស់តុលាការអន្តរជាតិ ។ វិធានទាំងនេះកំណត់ថា ជនជាប់ចោទទាំងអស់*ត្រូវ*បានឃុំខ្លួនជាដំលើកបូង ហើយបន្ទុកនៃការបង្ហាញជាបន្តបន្ទាប់ដែលថា ការដោះលែងគឺជាការសមស្រប គឺជាបន្ទុករបស់មេធាវីការពារក្តីទាំងស្រុង[24]។ ផ្ទុយទៅវិញ អ.វ.ត.ក បានអនុម័តយកវិធីសាស្ត្រមួយដែលផ្តល់ឆន្ទានុសិទ្ធិច្រើនឱ្យ ក.ស.ច.ស សម្រេចថាតើត្រូវឃុំខ្លួនបណ្ដោះអាសន្ន ឬ ត្រូវដោះលែងជនត្រូវចោទ ឬ យ៉ាងណានោះ គឺអាស្រ័យទៅលើការវិភាគដំបូងនៃល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង[25]។ ភាសានៃវិធាននេះ- ដែលល្បីល្បាញនៅក្នុងតុលាការអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល ដែលសំអាងទៅលើការវិភាគរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប- បានសន្និដ្ឋានយ៉ាងច្បាស់ថា វិធាននេះត្រូវបានតាក់តែងឡើងដោយមានការពិចារណាលើយុត្តិសាស្ត្រសិទ្ធិមនុស្ស ។

---

[23] *សូមមើល ឧទាហរណ៍* Anne Heindel ដែលជាទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា "ការបន្តការឃុំខ្លួន នួន ជា" ("យុត្តិសាស្ត្ររបស់ស្ថាប័នសិទ្ធិមនុស្ស មានដូចជា គណៈកម្មាធិការអន្តរៈអាមេរិកកាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប និង គណៈកម្មាធិការសិទ្ធិមនុស្សមិនពេញចិត្តចំពោះការឃុំខ្លួនបណ្ដោះអាសន្ន ហើយបានដាក់បន្ទុកទៅលើរដ្ឋឱ្យធ្វើយុត្តិកម្មចំពោះការ បន្តឃុំខ្លួននេះ។ ផ្ទុយទៅវិញ តុលាការព្រហ្មទណ្ឌអន្តរជាតិ និង តុលាការកូនកាន់បានលើកឡើងថា ការដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នគឺជាអញ្ញត្រកម្ម ហើយនៅក្នុងការអនុវត្តជាក់ស្តែង បានដាក់បន្ទុកទៅលើមេធាវីការពារក្តីឱ្យបង្ហាញថា ការដោះលែង ត្រូវបានអនុញ្ញាត"។

[24] *សូមមើល* វិធានទី ៦៤ របស់ ICTY, ICTR និង SCSL ("ក្រោយពីត្រូវបានបញ្ជូនមកកាន់តុលាការ ជនជាប់ចោទ *ត្រូវបានឃុំ ខ្លួន*នៅក្នុងមន្ទីរឃុំឃាំងដែលផ្តល់ដោយប្រទេសសាមី ឬ ដោយប្រទេសមួយផ្សេងទៀត") និង វិធានទី ៦៥(ក) ("បន្ទាប់ពីបានឃុំខ្លួន ជនជាប់ចោទមិនអាចត្រូវបានដោះលែងបានទេ លើកលែងតែមានដីកាដីលែងពីអង្គជំនុំជម្រះ")។ (មានបន្ថែមសេចក្តី បញ្ជាក់)។

[25] *សូមមើល*វិធាន ៦៣(១)(ក) ("សហចៅក្រមស៊ើបអង្កេត*អាច*សម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន ក្រោយពេលមានសវនាការតទល់គ្នា។ [...] ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ជនត្រូវចោទត្រូវបានដោះលែង ឱ្យមានសេរីភាព។ (មានបន្ថែមសេចក្តី បញ្ជាក់)។

00232745

C 9/4/1



ហេតុដូច្នេះ ទាក់ទងទៅនឹងលក្ខណៈខុសគ្នាដែលបានលើកឡើងខាងលើ តុលាការនេះគួរតែផ្តល់ការពិចារណាឲ្យបានទាន់ពេលវេលាចំពោះគោលការណ៍ដែលបានបង្កើតឡើង ដូចខាងក្រោមនេះ។

14. ច្បាប់សិទ្ធិមនុស្សទទួលស្គាល់ថា "ភស្តុតាងមួយក្រឡេកក្នែកផ្តល់សិទ្ធិទទួលបានការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងពេលរង់ចាំសវនាការ"[26]។ ដោយសារការឃុំខ្លួនបុគ្គលម្នាក់ដែលត្រូវគេបានសន្មត់ថាគ្មានទោសទុកជាមុន គឺជាវិធានការធ្ងន់ធ្ងរ នោះគេអាចធ្វើយុត្តិកម្មបានតែក្នុងករណីដែលជម្រើសមានលក្ខណៈមិនសូវធ្ងន់ធ្ងរ ត្រូវបានយកមកពិចារណា និងបានរកឃើញថាមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីធានាការពារដល់ផលប្រយោជន៍បុគ្គលណាម្នាក់ ឬផលប្រយោជន៍សាធារណៈ បានតែប៉ុណ្ណោះ[27]។ ប្រសិនការសុំដាក់ឲ្យស្ថិតនៅក្រោមផ្លូវតុលាការត្រូវបានបដិសេធភ្លាមៗ នោះជនត្រូវចោទមានសិទ្ធិ "ឲ្យព្រះរាជអាជ្ញា និង តុលាការចាត់ការលើរឿងក្តីរបស់ខ្លួនជាអាទិភាព"[28]។

## IV. **ឧត្តិករណ៍**

### **ក. បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន**

15. អនុលោមតាមវិធាន៦៣(៧) និង៧៤(៣)(ច) នៃវិធានផ្ទៃក្នុង បណ្តឹងឧទ្ធរណ៍នេះគឺអាចទទួលយកបាន។ លើសពីនេះទៅទៀត បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ជូននៅក្នុងអំឡុងពេលដែលកំណត់ដោយវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង។

### **ខ. មានមូលហេតុដែលនាំឲ្យជឿជាក់យ៉ាងច្បាស់ថា លោក នួន ជា អាចបានប្រព្រឹត្តឧក្រិដ្ឋទាំងអស់ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម**

---

[26] Simor និង Emerson, § 5.048; *សូមមើលដូចគ្នានេះផងដែរ* § 5.052 ("ជនជាប់ចោទដោយការប្រព្រឹត្តបទល្មើស ត្រូវតែដោះលែងដើម្បីរង់ចាំការកាត់សេចក្តីលើកលែងតែរដ្ឋអាចបង្ហាញថាមានហេតុផល 'ពាក់ព័ន្ធគ្រប់គ្រាន់' ដើម្បីធ្វើយុត្តិកម្មចំពោះការបន្តឃុំខ្លួនរូបគេបន្តទៅទៀត")។

[27] *សូមមើល ឧទាហរណ៍* រឿងក្តី *Jaworski* តទល់នឹង ប្រទេសប៉ូឡូញ តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តីលេខ ២៥៧១៥/០២ សាលក្រម ចុះថ្ងៃទី២៨ មីនា ២០០៦ (ហៅថា "សាលក្រម Jaworsk") ពីកថាខណ្ឌ ៤១ ដល់ ៤២ ។

[28] រឿងក្តីរវាង Simor តទល់នឹង Emerson, § 5.055។

00232746



16. ក្រោយពីតុលាការធ្វើការស៊ើបអង្កេតពេញមួយឆ្នាំរួចមក[29] យោងតាមស្តារីដ៏តឹងរ៉ឹងក្នុងវិធានផ្ទៃក្នុង ៦៣(៣)(ក)[30] មានមូលហេតុដែលនាំឱ្យជឿជាក់យ៉ាងច្បាស់ថា លោក **នួន ជា** អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ពាក់ព័ន្ធទៅនឹងសកម្មភាពរបស់មន្ទីរ ស-២១ តែប៉ុណ្ណោះ។ ទាក់ទងទៅនឹងការចោទប្រកាន់ផ្សេងៗទៀតដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ឃើញថាពុំមានភស្តុតាងណាមួយនៅក្នុងសំណុំរឿងអាចឱ្យអ្នកសង្កេតការណ៍ឥតលំអៀងយល់ស្របថា ការរៀបរាប់ពីព្រឹត្តិការណ៍របស់ ក.ស.ព គឺជា ការរៀបរាប់មួយដែលសុក្រឹត្យបាននោះទេ ហើយក៏មិនមានហេតុផលណាមួយដែលនាំឱ្យជឿជាក់ថា ឯកសារបែបនោះកំពុងតែមាននោះដែរ។ ក្រៅតែពី ឌុច ពុំមានសាក្សីណាម្នាក់ដែលសម្ភាសន៍ដោយ ក.ស.ច.ស[31] បានឆ្លើយទម្លាក់កំហុសមកលើលោក **នួន ជា** នៅក្នុងសកម្មភាពព្រហ្មទណ្ឌណាមួយនោះទេ[32]។ លើសពីនេះទៅទៀត ពុំមានឯកសារណាមួយដែល ក.ស.ច.ស[33] បានប្រមូល (ក្រៅតែពីឯកសារទាក់ទងនឹងមន្ទីរ ស-២១) បានភ្ជាប់លោក **នួន ជា** ទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយនោះទេ[34]។ ជាការគួរឱ្យជំទាស់តវ៉ាផងដែរ រឿងក្តីប្រឆាំងមកលើលោក **នួន ជា** មានកម្រិតចំពោះព្រឹត្តិហេតុដែលបានលើកឡើង ថាបានកើតឡើងដោយជាក់ពាក់ព័ន្ធជាមួយកិច្ចការរបស់មន្ទីរ ស-២១ នោះគឺមិនបានកើតឡើងទាល់តែសោះ។

## គ. ពុំមានមូលហេតុបន្ថែមដើម្បីធ្វើយុត្តិកម្មដល់ការឃុំខ្លួនបណ្តោះអាសន្ន

---

[29] *សូមមើល* ឯកសារលេខ D-២៥, D-៤០, D-៤៣, D-៦៨, D-៨២, D-៨៦, D-៩០, D-៩១, D-៩២, D-៩៣, D-៩៤, D-៩៥, និងឯកសារឆ្លើយឆ្លងផ្សេងទៀត។

[30] ដោយទុកចោលមួយឡែកនូវការទទួលយកបាន ទម្ងន់ និង/ឬ ភាពគួរឱ្យជឿជាក់បាននៃឯកសារដែលកំពុងតែមាននៅក្នុងសំណុំរឿង នោះគឺថា មិនទាន់មានឯកសារណាមួយត្រូវបានយកមកធ្វើតេស្ត ឬ ត្រូវបានជំទាស់នៅឡើយទេ។ សូមចំណាំ: មេធាវីការពារក្តី ពិចារណាពីភាពគួរឱ្យជឿជាក់បាននៃកំណត់ហេតុស្តាប់ចម្លើយ ឌុច ថាមានការគួរឱ្យសង្ស័យយ៉ាងខ្លាំង ហើយទាក់ទងនឹងបញ្ហានេះ ទំនងជានឹងដាក់សារណាបន្ថែមទៀតទៅ ក.ស.ច.ស ។

[31] *សូមមើល* ឯកសារលេខ D-២៥, D-៤០, D-៦៨, D-៨៦, D-៩១, D-៩២, D-៩៣, D-៩៤, និងឯកសារឆ្លើយឆ្លងផ្សេងទៀត។

[32] *ចំណាំ:* ក្នុងចំណោមឯកសារទាំងអស់នេះ មានឯកសារខ្លះមិនទាន់បានបកប្រែទៅជាភាសាអង់គ្លេសនៅឡើយទេ។

[33] *សូមមើល* ឯកសារលេខ D-៤៣, D-៨២ និង ឯកសារឆ្លើយឆ្លងផ្សេងទៀត។

[34] *ចំណាំ:* ក្នុងចំណោមឯកសារទាំងអស់នេះ មានឯកសារខ្លះមិនទាន់បានបកប្រែទៅជាភាសាអង់គ្លេសនៅឡើយទេ។

## លោក នួន ជា បន្តទៅទៀតនោះទេ

17. អត្ថិភាពនៃមូលហេតុដែលនាំឱ្យជឿជាក់យ៉ាងច្បាស់តែម្យ៉ាងថា លោក នួន ជា បានប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើននោះ គឺមិនគ្រប់គ្រាន់ដើម្បីគាំទ្រដល់ដីកាសម្រេចឃុំខ្លួនជាបណ្តោះអាសន្ននោះទេ។ ក្នុងន័យនេះហើយ មេធាវីការពារស្នើសុំឱ្យដាក់បញ្ចូលសារណាដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន[35]និងស្នើសុំឱ្យលើកយកសារណាទាំងនេះមកពិចារណាជាថ្មី។ យោងតាមយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបដែលបានលើកឡើងខាងលើ ជាពិសេសទទ្បីករណីដែលទាក់ទងទៅនឹងវិធានផ្ទៃក្នុងទី ៦៣(៣)(ខ)(i) និង (ii) កាន់តែធ្វើឱ្យមានទម្ងន់ថែមទៀត ដោយសារថា ក.ស.ច.ស បានចំណាយពេលពេញមួយឆ្នាំក្នុងការស៊ើបអង្កេតរបស់ខ្លួន ។ ជំនួសឱ្យសមាមាត្រភាពដែលបានទទួលស្គាល់យ៉ាងច្បាស់នេះ ក.ស.ច.ស បានខកខានមិនបានពន្យល់ថាតើហានិភ័យ *ដែលត្រូវបានបង្កើតជាទូទៅ* ដែលត្រូវបានយកមកធ្វើយុត្តិកម្មចំពោះការឃុំខ្លួនលោក នួន ជា លើកដំបូង ត្រូវបានគាំទ្រដោយភស្តុតាង*ភស្តុតាងរឹងមាំ* ដូចដែលបានតម្រូវដែរឬយ៉ាងណា។

## ឃ. ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនបានបញ្ជាក់ពីមូលដ្ឋានអង្គហេតុសម្រាប់ការឃុំខ្លួនលោក នួន ជា នោះទេ

18. ក.ស.ច.ស បានបញ្ជាក់ជាចុងក្រោយថា លោក នួន ជា កំពុងត្រូវបានឃុំខ្លួនដោយសំអាងទៅលើអំណាចនៃការអះអាងតាមការយល់ឃើញដែលថា គាត់អាចទទួលខុសត្រូវដោយផ្ទាល់ និង/ឬទទួលខុសត្រូវជាថ្នាក់លើចំពោះការកាប់សម្លាប់ អំពើធ្វើទារុណកម្ម អំពើបំពារបំពានលើរូបកាយ និង/ឬ ផ្លូវចិត្ត ដែលថាបានកើតមានឡើងជាប់ទាក់ទងទៅនឹងកិច្ចការរបស់មន្ទីរ ស-២១[36] ។ នេះគ្រាន់តែជាការផ្លាស់ប្តូរមួយក្នុងចំណោមការផ្លាស់ប្តូរជាច្រើន ដែលកើតចេញពីការចោទប្រកាន់របស់ ក.ស.ព ហើយមិនមានការវាយតម្លៃជាក់លាក់ដោយ ក.ស.ច.ស ពាក់ព័ន្ធទៅនឹង

[35] *សូមមើល* បណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ពីកថាខណ្ឌ ៤៤ ដល់ ៥៣ ។

[36] *សូមមើល* ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ទំព័រ ២ ។

បទចោទដទៃទៀតដែលនឹងមាននាពេលខាងមុខនេះ[37]។ ការខកខាននេះបណ្ដាលឱ្យមានការចាប់អារម្មណ៍ថា មិនមានមូលហេតុដែលនាំឱ្យជឿជាក់យ៉ាងច្បាស់ថា លោក នួន ជា ទទួលខុសត្រូវចំពោះការចោទប្រកាន់បន្ថែមទៀតនោះទេ។ ទោះជាយ៉ាងណាក៏ដោយ មេធាវីការពារសង្ស័យយ៉ាងខ្លាំងថានេះគឺជាជំហររបស់ ក.ស.ច.ស តែប៉ុណ្ណោះ។

19. កាន់តែច្របូកច្របល់ថែមទៀតនោះ គឺការអនុវត្តការវិភាគទៅលើវិធានផ្ទៃក្នុងទី ៦៣(៣)(ខ) យ៉ាងប្រញាប់ប្រញាល់របស់ ក.ស.ព។ ក្នុងខណៈដែលវិធានទាំងឡាយ និង យុត្តិសាស្ត្រស្តីពីសិទ្ធិមនុស្សពាក់ព័ន្ធ តម្រូវឱ្យ ក.ស.ច.ស ដាក់ចេញនូវសេចក្តីសម្រេចប្រកបដោយហេតុផលឱ្យលើសពីការសំអាងទៅលើបទប្បញ្ញត្តិច្បាប់នៅជាធរមានតែមួយចំនុច នោះដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នគ្រាន់តែចង្អុលបង្ហាញថា "លក្ខខណ្ឌដែលមានចែងនៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុងនៅតែបំពេញបាននៅឡើយ។ ហេតុដូច្នេះ ហេតុផលរបស់អង្គបុរេជំនុំជម្រះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២០ មីនា ២០០៨ នៅតែមានសុពលភាពដដែល"[38]។ ដោយហេតុថា នេះគ្រាន់តែជាការវាយតម្លៃគំរប់កិច្ច ហេតុដូច្នេះ គេអាចសន្និដ្ឋានថាមិនមានការវិភាគបន្ថែមទៅលើចំនុចសំខាន់នេះទេ។

20. សរុបមក ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានរៀបរាប់យ៉ាងល្អជាការយល់ស្របទៅលើសេចក្តីសម្រេចចាស់ ដែលមិនអាចរិះគន់បាន។ គោលបំណងនៃការពិនិត្យឡើងវិញជាទៀងទាត់លើបញ្ហាឃុំខ្លួនបណ្តោះអាសន្ននេះ គឺដើម្បីវាយតម្លៃស្ថានភាពសារជាថ្មី និងមិនគ្រាន់តែធ្វើដីកាចាស់មួយឱ្យរស់ឡើងវិញ ដូចដែល ក.ស.ច.ស បានធ្វើនោះទេ។ ជាអកុសលភាពហ្មត់ចត់ក្នុងការវិភាគដែលតែងតែជាប់ទាក់ទិនជាមួយដំណើរការរបស់តុលាការ ហាក់ដូចជាត្រូវបានដាក់ជំនួសដោយវិធីសាស្ត្របែបប្រថាប់ត្រាក្នុងការវាយតម្លៃទៅលើ"ភស្តុតាង"។ សេចក្តីគោរពចំពោះឧត្តមគតិដែលមាន ដែលជាការរំពឹងទុកពី ក.ស.ព និងភាគីរដ្ឋប្បវេណី គឺមិនស៊ី

---

[37] សូមកត់ចំណាំ: ដីកាដើមរបស់ ក.ស.ច.ស បានយោងតែទៅលើ "ឯកសារ និង កំណត់ហេតុស្តាប់ចម្លើយសាក្សីជាច្រើនដែលទម្លាក់កំហុសមកលើលោក នួន ជា" ដោយមិនមានចំនុចលំអិតបន្ថែមទៀតនោះឡើយ។ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី ៥ ។

[38] ដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ទំព័រ ២ ។

សង្ខាក់ទាំងស្រុងជាមួយការបំពេញភារកិច្ចរបស់ ក.ស.ច.ស ដោយ"ឥតលំអៀង"[39]។ សេចក្តីសម្រេចរបស់តុលាការ ដូចជាដីកាសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នបានបង្ហាញឱ្យឃើញពីការគ្មានសមត្ថភាព ឬ ការគ្មានឆន្ទៈដើម្បីប្រយុទ្ធតទល់ជាមួយបញ្ហាទាំងនេះ ដែលជាហេតុនាំឱ្យមានការមន្ទិលសង្ស័យកាន់តែខ្លាំងឡើងចំពោះការប្តេជ្ញាចិត្តរបស់តុលាការក្នុងការ "ស្វែងរកការពិត"នោះ[40]។

## ឃ. ការដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នដោយភ្ជាប់លក្ខខណ្ឌនានា គឺជាការសមស្រប

21. ទាំង ក.ស.ច.ស ទាំងអង្គបុរេជំនុំជម្រះ មិនបានពិចារណាឱ្យបានហ្មត់ចត់ពីការកំណត់ឱ្យមានវិធានការធូរស្រាលមួយ ដែលបង្កើតឡើងដើម្បីសម្រួលដល់វិធាន ៦៣(៣)(ខ) ដែលគេទទួលស្គាល់ជារួមរួចមកហើយនោះ ។ ដោយមិនមានការពន្យល់លំអិត ស្ថាប័នតុលាការទាំងពីរនេះគ្រាន់តែបានលើកឡើងថា ពុំមានដីកាដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការអាចការពារផលប្រយោជន៍សាធារណៈឱ្យបានម៉ឺងម៉ាត់គ្រប់គ្រាន់បាននោះទេ[41]។ សច្ចធារណ៏នៃនីរទោសតម្រូវឱ្យមានការវិភាគស្រាវជ្រាវកាន់ច្រើនឡើង ដោយសំអាងទៅលើមូលហេតុនៅក្នុងតថភាពអនុវត្តជាក់ស្តែងនៃរឿងក្តីនេះ។ ឧបមាថា (តែមិនយល់ស្រប) ការព្រួយបារម្ភដែលបានលើកឡើងមកដល់ពេលនេះ ពី"ការឃុំខ្លួននៅក្នុងផ្ទះ" ដែលស្ថិតនៅឯមន្ទីរពេទ្យណាមួយដែលអាចយល់ព្រមនៅកណ្តាលទីក្រុងភ្នំពេញ អាចដោះស្រាយបញ្ហាទាំងនេះប្រកបដោយប្រសិទ្ធិភាពដូចគ្នាទៅនឹងការបន្តការឃុំខ្លួននៅក្នុងបរិវេណ អ.វ.ត.ក ដូច្នោះដែរ។ ជម្រើសនេះអាចផ្តល់ផលប្រយោជន៍បន្ថែមទៀតដល់លោក **នួន ជា** ឱ្យទទួលបានសេវាពេទ្យជាបន្ទាន់ ដែលស្ថិតនៅជិតបំផុតនោះគឺជាការប្រសើរ[42] ដែលសព្វថ្ងៃនេះត្រូវចំណាយពេលសែសិបប្រាំនាទីយ៉ាងលឿនដើម្បីឱ្យទៅដល់ទីនោះ។

---

[39] វិធានទី ៥៥(៥) នៃវិធានផ្ទៃក្នុង ។

[40] វិធានទី ៥៥(៥) នៃវិធានផ្ទៃក្នុង ។

[41] *សូមមើល* ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី ៦ ។ សេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី ៨៣ ។

[42] មនុស្សគ្រប់រូបដែលដែលធ្លាប់ធ្វើដំណើរប្រចាំថ្ងៃពីភ្នំពេញមកបរិវេណ អ.វ.ត.ក គឺពិតជាដឹងយ៉ាងច្បាស់ថា នៅពេលដែលមាន ចរាចរកកស្ទះខ្លាំងមែនទែន នោះការធ្វើដំណើរអាចចំណាយពេលជាងពីរឯណោះ។ *សូមមើល* ឯកសារលេខ C-៣៩ "កំណត់ហេតុសម្ភាសន៍ជាលាយលក្ខអក្សរស្តីពីស្ថានភាពនៃការឃុំខ្លួន ចុះថ្ងៃទី១៣ តុលា ២០០៨ ទំព័រទី២

ដូចដែលបានជំទាស់តវ៉ាពីមុនរួចមកហើយ "មានមូលហេតុជាក់លាក់ដែលអាចឱ្យជឿបានថា អាជ្ញាធរ [កម្ពុជា] មានលទ្ធភាពខ្ពស់ក្នុងការឃ្លាំមើល [...] បុរសម្នាក់ដែលស្ថិតក្នុងស្ថានភាពចាស់ជរា ដូចរូប[43]លោក **នួន ជា** នេះ"។

## V. សេចក្តីសន្និដ្ឋាន

22. អាស្រ័យដោយមូលហេតុដូចដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសំណូមពរឱ្យអង្គបុរេជំនុំជម្រះលប់ចោលដីកាសម្រេចអំពីការបន្តថេរះវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និងដោះលែងលោក **នួន ជា** ស្របតាមល័ក្ខខ័ណ្ឌនានា ដែលបានលើកឡើងរួចមកហើយ នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។ ជាជម្រើស អង្គបុរេជំនុំជម្រះគួរធ្វើការរៀបចំចាត់ចែងជាចាំបាច់សម្រាប់ការបញ្ជូនលោក **នួន ជា** ទៅកាន់មន្ទីរពេទ្យណាមួយដែលអាចយល់ព្រមនៅកណ្តាលទីក្រុងភ្នំពេញ និងក្នុងករណីខ្លះ អង្គបុរេជំនុំជម្រះគួរណែនាំ ក.ស.ច.ស ឱ្យអនុលោមតាមសេចក្តីព្រាងការអនុវត្តរបស់ខ្លួនចំពោះវិធានទាំងឡាយដែលនៅជាធរមាន និងយុត្តិសាស្ត្រពាក់ព័ន្ធ។

សហមេធាវីរបស់ នួន ជា

សុន អរុណ

Michiel PESTMAN និង Victor KOPPE

P.P.

---

(ដែលមេធាវីការពារ បានស្នើសុំឱ្យផ្តល់ឧទ្ធម្ភាគចក្រមួយគ្រឿង ក្នុងករណីមានសេចក្តីត្រូវការដឹកជញ្ជូនទៅកាន់សេវាពេទ្យជាបន្ទាន់។

[43] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌទី ៥៧។